**ក្រុមហ៊ុន ឥណទានពលរដ្ឋរុងរឿង អិលធីឌី**
(ចុះបញ្ជីពាណិជ្ជកម្មលេខ ០០០១៧៦៤៣)

# របាយការណ៍ក្រុមប្រឹក្សាភិបាល និង
# របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម
# សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

**ក្រុមហ៊ុន ឥណទានពលរដ្ឋរុងរឿង អិលធីឌី**

**របាយការណ៍ក្រុមប្រឹក្សាភិបាល និង របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦**

| **មាតិកា** | **ទំព័រ** |
| --- | --- |
| របាយការណ៍ក្រុមប្រឹក្សាភិបាល | ១ – ៤ |
| របាយការណ៍សវនករឯករាជ្យ | ៥ – ៧ |
| របាយការណ៍តុល្យការ | ៨ |
| របាយការណ៍លទ្ធផល | ៩ |
| របាយការណ៍បម្រែបម្រួលមូលធនភាគទុនិក | ១០ |
| របាយការណ៍លំហូរសាច់ប្រាក់ | ១១ – ១២ |
| កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ | ១៣ – ៥៥ |

ឥណទានពលរដ្ឋរុងរឿង អិលធីឌី
INTEAN POALROATH RONGROEURNG LTD

Address: # 779A, Kampuchea Kraom Blvd, Sangkat Tuek Laak 1, Khan Tuol Kouk, Phnom Penh, Cambodia.
Phone: 023 990 237, Fax: 023 950 211, Email: info@iprmfi.com, Website: www.iprmfi.com

## របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលមានក្តីសោមនស្សរីករាយ ក្នុងការបង្ហាញជូននូវរបាយការណ៍របស់ខ្លួន និង របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន **ឥណទានពលរដ្ឋរុងរឿង អិលធីឌី** ហៅកាត់ថា ("ក្រុមហ៊ុន") ដែលបានធ្វើ សវនកម្មសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦។

## សកម្មភាពចម្បង

សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុន គឺការផ្តល់សេវាមីក្រូហិរញ្ញវត្ថុជូនប្រជាពលរដ្ឋនៅតាមតំបន់ជនបទនៅក្នុងប្រទេសកម្ពុជា។ សេវាទាំងនោះរួមមានការផ្តល់ឥណទានជូនគ្រួសារក្រីក្រ និងគ្រួសារដែលមានប្រាក់ចំណូលទាប ក៏ដូចជាសហគ្រាសធុនតូច ដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផលនៅលើទំព័រទី៩ នៃរបាយការណ៍ហិរញ្ញវត្ថុ។

នៅថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ ភាគលាភចំនួន ១.៣០០.០០០ ដុល្លារអាមេរិក ត្រូវបានអនុម័តក្នុងសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។ ចំណាយភាគលាភចំនួន ១.០០០.០០០ ដុល្លារអាមេរិក និង ៣០០.០០០ ដុល្លារអាមេរិកត្រូវបានធ្វើនៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៦ និង ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៦ ជាបន្តបន្ទាប់។

## ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តទៅលើទុនបម្រុង និងសំវិធានធននៅក្នុងគ្រានេះទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

## ដើមទុន

ក្នុងអំឡុងឆ្នាំនេះ មិនមានបម្រែបម្រួលដើមទុនចុះបញ្ជី និងដើមទុនបានបង់របស់ក្រុមហ៊ុនទេ។

## ឥណទានអាក្រក់ និងឥណទានសង្ស័យ

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ពាក់ព័ន្ធទៅនឹងការជម្រះឥណទានអាក្រក់ចេញពីបញ្ជី ឬការធ្វើសំវិធានធនឥណទានអាក្រក់ និងសង្ស័យ ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថារាល់ឥណទានអាក្រក់ទាំងអស់ដែលបានដឹងត្រូវបានជម្រះចេញពីបញ្ជី និងបានកត់ត្រាសំវិធានធនយ៉ាងពេញលេញសម្រាប់ឥណទានអាក្រក់ និងសង្ស័យ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកទៅតាមកម្រិតនៃការយល់ដឹងរបស់ខ្លួន ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលនាំឲ្យចំនួនសំវិធានធនឥណទានអាក្រក់ និងសង្ស័យ ក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមានតម្លៃមិនគ្រប់គ្រាន់ជាសារវន្តនោះទេ។

## ទ្រព្យសកម្ម

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថាបណ្តាទ្រព្យសកម្មទាំងឡាយ ដែលទំនងជាមិនអាចបង្វិលមកវិញនៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ទៅតាមតម្លៃនៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ត្រូវបានកត់ត្រាបន្ថយឱ្យនៅស្មើនឹងតម្លៃដែលរំពឹងគិតថានឹងអាចទទួលស្គាល់បានជាក់ស្តែង។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលអាចបណ្តាលឱ្យតម្លៃទ្រព្យសកម្មក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនពុំត្រឹមត្រូវជាសារវន្តទេ។

## វិធីសាស្ត្រវាយតម្លៃ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកទៅតាមកម្រិតនៃការយល់ដឹងរបស់ខ្លួន ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយដែលបានកើតឡើង ហើយអាចបណ្តាលឲ្យប៉ះពាល់ដល់វិធីសាស្ត្រវាយតម្លៃទ្រព្យសកម្ម និងបំណុលដែលមានស្រាប់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមានភាពមិនត្រឹមត្រូវ ឬមិនសមស្របជាសារវន្តនោះទេ។

## បំណុលយថាភាព និងបំណុលផ្សេងៗ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ មិនមាន៖

ក. បន្ទុកណាមួយលើទ្រព្យសកម្មរបស់ក្រុមហ៊ុន ដែលបានកើតឡើងដោយសារការដាក់វាបញ្ចាំសម្រាប់ការធានាបំណុលរបស់បុគ្គលណាម្នាក់ឡើយចាប់តាំងពីដំណាច់ឆ្នាំមក និង

ខ. បំណុលយថាភាពណាមួយរបស់ក្រុមហ៊ុនដែលបានកើតឡើងចាប់តាំងពីដំណាច់ឆ្នាំមក ក្រៅពីបំណុលផ្សេងៗ នៅក្នុងដំណើរការអាជីវកម្មក្រុមហ៊ុនធម្មតានោះទេ។

## ការប្រែប្រួលកាលៈទេសៈ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលមិនបានដឹងពីកាលៈទេសៈណាមួយដែលមិនបានវែកញែកនៅក្នុងរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលអាចបណ្តាលឱ្យចំនួនទឹកប្រាក់ដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុមានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ។

## ប្រតិបត្តិការមិនប្រក្រតី

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ មិនបានទទួលរងនូវផលប៉ះពាល់ជាសារវន្តពីខ្ទង់គណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍មិនប្រក្រតីណាមួយឡើយ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល នៅចន្លោះពេលរវាងដំណាច់ឆ្នាំនេះរហូតមកទល់នឹងកាលបរិច្ឆេទនៃរបាយការណ៍ មិនមានខ្ទង់គណនីប្រតិបត្តិការ ឬព្រឹត្តិការណ៍ខុសប្រក្រតីណាមួយដែលអាចជះឥទ្ធិពលជាសារវន្តដល់លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនក្នុងឆ្នាំ ដែលរបាយការណ៍នេះត្រូវបានធ្វើឡើងនោះទេ។

## ព្រឹត្តិការណ៍សំខាន់ៗ

មិនមានព្រឹត្តិការណ៍សំខាន់ៗបានកើតឡើងបន្ទាប់ពីកាលបរិច្ឆេទតារាងតុល្យការ ដែលតម្រូវឱ្យមានការលាតត្រដាង ឬនិយ័តកម្មក្រៅពីបណ្តាប្រតិបត្តិការផ្សេងៗដែលបានលាតត្រដាងនៅក្នុងកំណត់សម្គាល់ដែលបានភ្ជាប់មកជាមួយនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនោះទេ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាល ដែលនៅបម្រើការក្នុងអំឡុងឆ្នាំ រហូតដល់កាលបរិច្ឆេទនៃរបាយការណ៍នេះមានរាយនាមដូចខាងក្រោម៖

| | |
|---|---|
| ឧកញ៉ា ភួ ពុយ | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក ម៉ក់ សារុន | អភិបាល |
| លោក មិន គឹមសាន | អភិបាល |
| លោក Hsu Ming Yee | អភិបាលឯករាជ្យ |
| លោក ចាន់ សុផល | អភិបាលឯករាជ្យ |
| លោក មៅ សារិន | អភិបាលឯករាជ្យ |
| លោកស្រី ប៉ុក នីវីល័យ | អភិបាលឯករាជ្យ |

## ភាគហ៊ុនរបស់អភិបាល

អភិបាលដែលនៅបំរើការនាចុងកាលបរិច្ឆេទ និងមានភាគហ៊ុននៅក្នុងក្រុមហ៊ុនមានដូចខាងក្រោម៖

| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | |
|---|---|---|---|---|
| | កាន់កាប់ % | ចំនួនភាគហ៊ុន ១១៩ ដុល្លារអាមេរិកក្នុងមួយហ៊ុន | កាន់កាប់ % | ចំនួនភាគហ៊ុន ១១៩ ដុល្លារអាមេរិកក្នុងមួយហ៊ុន |
| ឧកញ៉ា ភួ ពុយ | ១០០% | ២៥,៩៥៥ | ១០០% | ២៥,៩៥៥ |

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល

នៅក្នុង និងនាចុងគ្រាហិរញ្ញវត្ថុនេះ ពុំមានការរៀបចំណាមួយដែលមានក្រុមហ៊ុនជាគូភាគីមួយក្នុងគោលបំណងជួយដល់សមាជិកក្រុមប្រឹក្សាភិបាល ដើម្បីទទួលបាននូវអត្ថប្រយោជន៍ដោយមធ្យោបាយទិញយកភាគហ៊ុននោះទេ។

ចាប់តាំងពីដើមគ្រាហិរញ្ញវត្ថុ ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់បានទទួល ឬមានសិទ្ធិទទួលបាននូវអត្ថប្រយោជន៍ណាមួយតាមរយៈការចុះកិច្ចសន្យាធ្វើឡើងដោយក្រុមហ៊ុនលើកលែងតែការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង និងបានបង្ហាញយ៉ាងត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ដំណាច់ឆ្នាំ។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះតម្រូវឲ្យក្រុមប្រឹក្សាភិបាលត្រូវ៖

- អនុវត្តគោលការណ៍គណនេយ្យសមស្រប ដែលគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ព្រមទាំងអនុវត្តតាមគោលការណ៍ទាំងនេះឱ្យមានភាពស៊ីសង្វាក់គ្នា។
- អនុវត្តតាមការតម្រូវ ក្នុងការលាតត្រដាងព័ត៌មាន ដែលអនុលោមតាមស្តង់ដារគណនេយ្យកម្ពុជា និង បទប្បញ្ញត្តិ និងគោលការណ៍ណែនាំទាក់ទងទៅនឹងគណនេយ្យ របស់ធនាគារជាតិនៃកម្ពុជា ហើយប្រសិនបើមានការប្រាសចាកណាមួយ ក្នុងការបង្ហាញ ឱ្យមានភាពពិត និងត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថា ការប្រាសចាកទាំងនោះត្រូវបានលាតត្រដាងពន្យល់ និងកំណត់បរិមាណយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។
- រក្សាទុកកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព។
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លុះត្រាតែមានករណីមិនសមរម្យណាមួយក្នុងការសន្មតថា ក្រុមហ៊ុននឹងមិនបន្តធ្វើប្រតិបត្តិការអាជីវកម្មនាពេលអនាគត។
- ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឲ្យមានប្រសិទ្ធភាព និងចូលរួមរាល់សេចក្តីសម្រេចសំខាន់ៗទាំងឡាយណាដែលប៉ះពាល់ដល់សកម្មភាពប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថា កិច្ចការនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលអះអាងថា ក្រុមហ៊ុនបានអនុវត្តតាមតម្រូវការខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## សេចក្តីថ្លែងរបស់ក្រុមប្រឹក្សាភិបាល

របាយការណ៍ហិរញ្ញវត្ថុ បានបង្ហាញយ៉ាងត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ នៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរ សាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ហើយគិតត្រឹមកាលបរិច្ឆេទចេញផ្សាយរបាយការណ៍នេះក្រុមប្រឹក្សាភិបាលជឿជាក់ថា ក្រុមហ៊ុនមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការទូទាត់បំណុលនៅពេលដល់កំណត់សង។

ចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សាភិបាល

INTEAN POALROATH RONGROEUNG LTD.

ឧកញ៉ា ភូ ពុយ
ប្រធានក្រុមប្រឹក្សាភិបាល

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
កាលបរិច្ឆេទ៖ ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧

# Deloitte.

Deloitte (Cambodia) Co., Ltd.
Vattanac Capital Tower
Floor 8, Unit 8, #66
Preah Monivong Blvd
Sangkat Wat Phnom
Khan Duan Penh
Phnom Penh, Cambodia

Tel: +855 (0) 23 963 777
Fax: +855 (0) 23 963 778
www.deloitte.com/kh

## របាយការណ៍សវនករឯករាជ្យ
## ជូនភាគទុនិក ក្រុមហ៊ុន ឥណទានពលរដ្ឋរុងរឿង អិលធីឌី

### មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន **ឥណទានពលរដ្ឋរុងរឿង អិលធីឌី** (ហៅកាត់ថា "ក្រុមហ៊ុន") ដែលរួមមានតារាងតុល្យការនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ និងរបាយការណ៍លទ្ធផល របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ព្រមទាំងកំណត់សម្គាល់ ដែលរួមមានសេចក្តីសង្ខេបនៃគោលការណ៍គណនេយ្យសំខាន់ៗ និងព័ត៌មានពន្យល់ដទៃទៀតដែលបានបង្ហាញនៅទំព័រទី ៨ ដល់ ៥៥។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុ បានបង្ហាញនូវភាពត្រឹមត្រូវជាសារវន្តនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន **ឥណទានពលរដ្ឋរុងរឿង អិលធីឌី** នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និង លំហូរសាច់ប្រាក់របស់ក្រុមហ៊ុន សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងបទប្បញ្ញត្តិ និងគោលការណ៍ណែនាំទាក់ទងទៅនឹងគណនេយ្យរបស់ធនាគារជាតិនៃកម្ពុជា។

### មូលដ្ឋានសម្រាប់ការផ្តល់មតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា។ ការទទួលខុសត្រូវរបស់យើងខ្ញុំ ដោយអនុលោមទៅតាមស្តង់ដារទាំងនេះ គឺត្រូវបានរៀបរាប់នៅក្នុងផ្នែក *ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ* នៃរបាយការណ៍នេះ។ យើងខ្ញុំឯករាជ្យពីក្រុមហ៊ុន ដោយអនុលោមទៅតាមការតម្រូវក្រមសីលធម៌ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុនៅប្រទេសកម្ពុជា ព្រមទាំងបានបំពេញនូវការទទួលខុសត្រូវលើក្រមសីលធម៌ផ្សេងៗទៀត ដោយអនុលោមទៅតាមការតម្រូវទាំងនេះ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងបានទទួលគឺគ្រប់គ្រាន់ និងសមរម្យ ដើម្បីផ្តល់ជាមូលដ្ឋានសម្រាប់ការផ្តល់មតិរបស់យើងខ្ញុំ។

### បញ្ហាផ្សេងៗ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ត្រូវបានធ្វើសវនកម្មដោយក្រុមហ៊ុនសវនកម្មផ្សេងទៀត ដែលបានបញ្ចេញមតិសវនកម្មនៅថ្ងៃទី៥ ខែមេសា ឆ្នាំ ២០១៦ ថារបាយការណ៍ហិរញ្ញវត្ថុនោះមានភាពត្រឹមត្រូវ។

### ព័ត៌មានផ្សេងៗដែលមិនមែនជារបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនករ

គណៈគ្រប់គ្រងទទួលខុសត្រូវទៅលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗរបស់ក្រុមហ៊ុនរួមមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលពីទំព័រទី ១ ទៅទំព័រទី ៤។

មតិយោបល់របស់យើងខ្ញុំ លើរបាយការណ៍ហិរញ្ញវត្ថុមិនគ្របដណ្តប់ព័ត៌មានផ្សេងៗ ហើយយើងខ្ញុំមិនបានធ្វើការសន្និដ្ឋានអះអាងលើព័ត៌មានផ្សេងៗឡើយ។

Deloitte refers to one or more of Deloitte Touche Tohmatsu Limited, a UK private company limited by guarantee ("DTTL"), its network of member firms, and their related entities. DTTL and each of its member firms are legally separate and independent entities. DTTL (also referred to as "Deloitte Global") does not provide services to clients. Please see www.deloitte.com/kh/about to learn more about our global network of member firms.

Deloitte.

ទាក់ទងទៅនឹងការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំគឺអានព័ត៌មានផ្សេងៗ និងពិចារណាថាតើព័ត៌មានផ្សេងៗទាំងនោះ មិនស្របគ្នាជាមួយរបាយការណ៍ហិរញ្ញវត្ថុជាសារវន្ត ឬជាមួយចំណេះដឹងរបស់យើងខ្ញុំដែលទទួលបានពីការធ្វើសវនកម្ម ឬកើតឡើងពីកំហុសឆ្គងជាសារវន្ត។ ប្រសិនបើផ្អែកទៅលើការងាររបស់យើងខ្ញុំដែលបានអនុវត្ត ហើយសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តលើព័ត៌មានផ្សេងៗ យើងខ្ញុំនឹងធ្វើការរាយការណ៍អំពីភាពជាក់ស្តែងនោះ។ យើងខ្ញុំមិនមានអ្វីត្រូវរាយការណ៍ឡើយ។

## ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងទទួលខុសត្រូវលើការរៀបចំ និងបង្ហាញភាពត្រឹមត្រូវលើរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងបទប្បញ្ញត្តិ និងគោលការណ៍ណែនាំទាក់ទងទៅនឹងគណនេយ្យរបស់ធនាគារជាតិនៃកម្ពុជា និងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងកំណត់ថាមានភាពចាំបាច់សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឲ្យជៀសផុតពីការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការប៉ាន់ប្រមាណពីលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្ម ការបង្ហាញបញ្ហាដែលពាក់ព័ន្ធនឹងការបន្តនិរន្តរភាពប្រសិនបើមាន និងការប្រើប្រាស់មូលដ្ឋាននិរន្តរភាពគណនេយ្យ លើកលែងតែគណៈគ្រប់គ្រងមានបំណងរំលាយក្រុមហ៊ុន ឬបញ្ឈប់អាជីវកម្ម ឬមិនមានជម្រើសជាក់ស្តែងណាមួយក្រៅពីអនុវត្តដូច្នោះ។

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវលើការត្រួតពិនិត្យដំណើរការ នៃការរាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ការទទួលខុសត្រូវរបស់សវនករចំពោះការធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបានអំណះអំណាងដែលសមហេតុផលថាតើរបាយការណ៍ហិរញ្ញវត្ថុជារួម គឺមិនមានកំហុសឆ្គងជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គង និងដើម្បីបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដែលរួមបញ្ចូលមតិយោបល់របស់យើងខ្ញុំ។ អំណះអំណាងដែលសមហេតុផលគឺជាអំណះអំណាងកំរិតខ្ពស់ ប៉ុន្តែមិនមែនជាការធានាថាការធ្វើសវនកម្មអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជានឹងតែងតែរកឃើញកំហុសឆ្គងជាសារវន្តនៅពេលដែលវាមាននោះទេ។ កំហុសឆ្គងនេះអាចកើតឡើងពីការក្លែងបន្លំ ឬកំហុសឆ្គងដែលត្រូវបានពិចារណាជាកំហុសឆ្គងជាសារវន្ត ប្រសិនបើកំហុសនីមួយៗ ឬកំហុសសរុប មានឥទ្ធិពលដល់ការសម្រេចចិត្តជាលក្ខណៈសេដ្ឋកិច្ច របស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុជាមូលដ្ឋាន។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងបានធ្វើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណតាមវិជ្ជាជីវៈ។ យើងខ្ញុំក៏បាន៖

- កំណត់ និងវាយតម្លៃហានិភ័យនៃកំហុសឆ្គងជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុទោះជាបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងក៏ដោយ កំណត់ និងអនុវត្តន៍និតិវិធីសវនកម្មដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ ដើម្បីទទួលបានភស្តុតាងពីការធ្វើសវនកម្មដែលគ្រប់គ្រាន់ និងសមរម្យ ដើម្បីផ្តល់ជាមូលដ្ឋានក្នុងការផ្តល់មតិយោបល់។ ហានិភ័យដែលមិនបានរកឃើញកំហុសឆ្គងជាសារវន្តពីការក្លែងបន្លំគឺធ្ងន់ធ្ងរជាងកំហុសឆ្គងធម្មតា ខណៈដែលការក្លែងបន្លំអាចបណ្តាលមកពីការឃុបឃិត ការក្លែង ការលុបចោលដោយចេតនា ការថ្លែងខុស ឬការបំពានលើការគ្រប់គ្រងផ្ទៃក្នុង។

Kl

- ទទួលបានការយល់ដឹងពីការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ដើម្បីរៀបចំនិតិវិធីសវនកម្មដែលសមរម្យទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនសំរាប់គោលបំណងបញ្ចេញមតិទៅលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ។
- វាយតម្លៃភាពត្រឹមត្រូវនៃគោលការណ៍គណនេយ្យដែលបានប្រើប្រាស់ ភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការបង្ហាញដែលពាក់ព័ន្ធនានាដោយគណៈគ្រប់គ្រង។
- សន្និដ្ឋានភាពសមហេតុផល មូលដ្ឋាននៃការប្រើប្រាស់គោលការណ៍គណនេយ្យនិរន្តរភាព នៃដំណើរការអាជីវកម្មរបស់គណៈគ្រប់គ្រង និងផ្អែកទៅលើភស្តុតាងសវនកម្មដែលបានទទួលថាតើភាពមិនប្រាកដជាសារវន្តកើតមានឡើងដែលពាក់ព័ន្ធនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចមានភាពមិនច្បាស់លាស់ទៅលើលទ្ធភាពរបស់ក្រុមហ៊ុន ដើម្បីបន្តនិរន្តរភាពនៃដំណើការអាជីវកម្ម។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំតម្រូវអោយមានការទាញចំណាប់អារម្មណ៍ នៅក្នុងរបាយការណ៍របស់សវនករទៅលើការបង្ហាញដែលពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការបង្ហាញមិនគ្រប់គ្រាន់ យើងខ្ញុំត្រូវបញ្ជាក់នៅក្នុងមតិយោបល់របស់យើងខ្ញុំ។ ការសន្និដ្ឋានរបស់យើងខ្ញុំផ្អែកទៅលើភស្តុតាងសវនកម្ម ដែលទទួលបានរហូតដល់ថ្ងៃនៃរបាយការណ៍សវនកម្ម។ ទោះជាយ៉ាងណា ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចបណ្តាលអោយក្រុមហ៊ុនបញ្ឈប់ការបន្តនិរន្តរភាព នៃដំណើការអាជីវកម្ម។
- វាយតម្លៃការបង្ហាញជារួម នៃរចនាសម្ព័ន្ធ និងខ្លឹមសារ នៃរបាយការណ៍ហិរញ្ញវត្ថុ រួមទាំងការបង្ហាញថាតើរបាយការណ៍ហិរញ្ញវត្ថុបង្ហាញប្រតិបត្តិការជាមូលដ្ឋាន និងព្រឹត្តិការណ៍នៅក្នុងការទទួលបានការបង្ហាញដែលត្រឹមត្រូវ។

យើងខ្ញុំទាក់ទងជាមួយក្រុមប្រឹក្សាភិបាល ពាក់ព័ន្ធទៅនឹងបញ្ហាផ្សេងៗ វិសាលភាព និងពេលវេលានៃការធ្វើសវនកម្ម និងការរកឃើញពីសវនកម្មសំខាន់ៗ រួមទាំងកង្វះខាតសំខាន់ៗនៃការត្រួតពិនិត្យផ្ទៃក្នុង ដែលបានរកឃើញនៅក្នុងអំឡុងពេលធ្វើសវនកម្មរបស់យើងខ្ញុំ។

តំណាងក្រុមហ៊ុន **ឌីឡយ្ធ៍ (ខេមបូឌា) ខូអិលធីឌី**

ខូយ គីមលេង
នាយក

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧

**ក្រុមហ៊ុន ឥណទានពលរដ្ឋខេមរៀង អិលធីឌី**

**តារាងតុល្យការ**
**គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦**

| | កំណត់ | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | |
|---|---|---|---|---|---|
| | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៤ | ៨៦.៣៧២ | ៣៤៨.៦៨៤ | ៩៤.៨៥២ | ៣៨៤.១៥១ |
| សមតុល្យនៅធនាគារជាតិ នៃកម្ពុជា | ៥ | ១៥៥.៦៨៨ | ៦២៨.៥១២ | ១៥៥.៣៨៣ | ៦២៩.៣០១ |
| សមតុល្យនៅធនាគារនានា | ៦ | ១.៥៨០.៩៦៧ | ៦.៣៨២.៣៦៤ | ២.២៤២.៧៨៦ | ៩.០៨៣.២៨៣ |
| ឥណទានផ្តល់ដល់អតិថិជន | ៧ | ១១.១១៥.៨៦៨ | ៤៤.៨៧៤.៧៥៩ | ៩.២២០.២៨១ | ៣៧.៣៤២.១៣៨ |
| ទ្រព្យសកម្មផ្សេងៗ | ៨ | ៤០៨.១៤២ | ១.៦៤៧.៦៦៩ | ៥១៣.២៧១ | ២.០៧៨.៧៥០ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ៩ | ៦៧.០៥៨ | ២៧០.៧១៣ | ៧៨.៤៩១ | ៣១៧.៨៨៩ |
| ទ្រព្យសកម្មអរូបី | ១០ | ១៦.៥៦៤ | ៦៦.៨៦៩ | ៤០.១៧០ | ១៦២.៦៨៩ |
| ឥណទានពន្ធលើប្រាក់ចំណេញ | ២០ (ក) | ២២.២២៧ | ៨៩.៧៣០ | ៦៣.៨៣៥ | ២៥៨.៥៣២ |
| ទ្រព្យសកម្មពន្ធពន្យារសុទ្ធ | ២០ (ខ) | ៧២.៩៦០ | ២៩៤.៥៤០ | ៨៩.០១៥ | ៣៦០.៥១១ |
| **សរុបទ្រព្យសកម្ម** | | ១៣.៥២៥.៨៤៦ | ៥៤.៦០៣.៨៤០ | ១២.៤៩៨.០៨៤ | ៥០.៦១៧.២៤៤ |
| **បំណុល និងមូលធន** | | | | | |
| **បំណុល** | | | | | |
| ប្រាក់កម្ចី | ១១ | ៦.២៩៧.១៥០ | ២៥.៤២១.៥៩៥ | ៤.៦១១.៩៦១ | ១៨.៦៧៨.៤៤២ |
| បំណុលផ្សេងៗ | ១២ | ២៦១.៩៩៨ | ១.០៥៧.៦៨៦ | ២៩១.២៨៦ | ១.១៧៩.៧១៣ |
| សំវិធានធនប្រាក់បំណាច់ការងារ | ១៣ | ១៤០.៧០៨ | ៥៦៨.០៣៨ | ១៣៧.៥២៧ | ៥៥៦.៩៨៤ |
| បំណុលពន្ធលើប្រាក់ចំណេញ ក្នុងឆ្នាំ | ២០ (គ) | ១៦៥.២៦៣ | ៦៦៧.១៦៧ | ១៦៨.៣២៦ | ៦៨១.៧២០ |
| **សរុបបំណុល** | | ៦.៨៦៥.១១៩ | ២៧.៧១៤.៤៨៦ | ៥.២០៩.១០០ | ២១.០៩៦.៨៥៩ |
| **មូលធនភាគទុនិក** | | | | | |
| ដើមទុន | ១៤ | ៣.០៨៨.៦៤៥ | ១២.៤៦៨.៨៦០ | ៣.០៨៨.៦៤៥ | ១២.៥០៩.០១២ |
| ចំណេញរក្សាទុក | | ៣.៥៧២.០៨២ | ១៤.៤២០.៤៩៤ | ៤.២០០.៣៣៩ | ១៧.០១១.៣៧៣ |
| **មូលធនភាគទុនិកសរុប** | | ៦.៦៦០.៧២៧ | ២៦.៨៨៩.៣៥៤ | ៧.២៨៨.៩៨៤ | ២៩.៥២០.៣៨៥ |
| **បំណុលនិងមូលធនភាគទុនិកសរុប** | | ១៣.៥២៥.៨៤៦ | ៥៤.៦០៣.៨៤០ | ១២.៤៩៨.០៨៤ | ៥០.៦១៧.២៤៤ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី ១៣ ដល់ទំព័រទី ៥៥ គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

**ក្រុមហ៊ុន ឥណទានពលរដ្ឋរុងរឿង អិលធីឌី**

**របាយការណ៍លទ្ធផល**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦**

| | កំណត់សម្គាល់ | សម្រាប់ដំណាច់ឆ្នាំត្រឹម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ដុល្លារអាមេរិក | ពាន់រៀល | សម្រាប់ដំណាច់ឆ្នាំត្រឹម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ដុល្លារអាមេរិក | ពាន់រៀល |
|---|---|---|---|---|---|
| ចំណូលការប្រាក់ | ១៥ | ២.៨៦១.៩២៨ | ១១.៥៥៣.៦០៣ | ២.៣៣៤.២៨៧ | ៩.៤៥៣.៨៦២ |
| ចំណាយការប្រាក់ | ១៦ | (៦១៥.៨៩៧) | (២.៤៨៦.៣៧៦) | (៣១៣.៥៦៦) | (១.២៦៩.៩៤២) |
| **ចំណូលពីការប្រាក់សុទ្ធ** | | ២.២៤៦.០៣១ | ៩.០៦៧.២២៧ | ២.០២០.៧២១ | ៨.១៨៣.៩២០ |
| ចំណូលពីប្រតិបត្តិការផ្សេងៗ | ១៧ | ៦១.០២៩ | ២៤៦.៣៧៤ | ៤៣.៨៣៩ | ១៧៧.៥៤៨ |
| **ចំណេញប្រតិបត្តិការ** | | ២.៣០៧.០៦០ | ៩.៣១៣.៦០១ | ២.០៦៤.៥៦០ | ៨.៣៦១.៤៦៨ |
| ចំណាយបុគ្គលិក | ១៨ | (៦៧២.៧៤៣) | (២.៧១៥.៨៦៣) | (៥៥៤.០៤៦) | (២.២៤៣.៨៨៦) |
| ចំណាយរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងទ្រព្យសកម្មអរូបី | | (៥៦.២២៨) | (២២៦.៩៩២) | (៥៥.៤៦៥) | (២២៤.៦៣៣) |
| ចំណាយផ្សេងៗ | ១៩ | (៥៤៣.១៨៦) | (២.១៩២.៨៤៣) | (៤៩២.២៧៧) | (១.៩៩៣.៧២២) |
| សំវិធានធនសម្រាប់ឥណទានអាក្រក់ និងជាប់សង្ស័យ | ៧ | (១០៨.០៨៨) | (៤៣៦.៣៥១) | (៩១.១៩៥) | (៣៦៩.១៣៧) |
| **ប្រាក់ចំណេញមុនដកពន្ធ** | | ៩២៦.៨១៥ | ៣.៧៤១.៥៥២ | ៨៧១.៦២៧ | ៣.៥៣០.០៩០ |
| ចំណាយពន្ធលើប្រាក់ចំណេញ | ២០ (ឃ) | (២៥៥.០៧២) | (១.០២៩.៧២៦) | (២០៥.១២៤) | (៨៣០.៧៥២) |
| **ប្រាក់ចំណេញសុទ្ធក្នុងគ្រា** | | ៦៧១.៧៤៣ | ២.៧១១.៨២៦ | ៦៦៦.៥០៣ | ២.៦៩៩.៣៣៨ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី ១៣ ដល់ទំព័រទី ៥៥ គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

**ក្រុមហ៊ុន ឥណទានពលរដ្ឋខេមរៀន អិលធីឌី**

## របាយការណ៍បម្រែបម្រួលមូលធនភាគទុនិក
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

| | ដើមទុន ដុល្លារអាមេរិក | ចំណេញរក្សាទុក ដុល្លារអាមេរិក | សរុប ដុល្លារអាមេរិក |
|---|---|---|---|
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០១៥ | ៣.០៨៨.៦៤៥ | ៣.៥៣៣.៨៣៦ | ៦.៦២២.៤៨១ |
| ចំណេញក្នុងឆ្នាំ | - | ៦៦៦.៥០៣ | ៦៦៦.៥០៣ |
| **សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥** | ៣.០៨៨.៦៤៥ | ៤.២០០.៣៣៩ | ៧.២៨៨.៩៨៤ |
| *សមមូលនឹងពាន់រៀល* | ១២.៥០៩.០១២ | ១៧.០១១.៣៧៣ | ២៩.៥២០.៣៨៥ |
| សមតុល្យគិតត្រឹមថ្ងៃទី១ ខែមករា ឆ្នាំ២០១៦ | ៣.០៨៨.៦៤៥ | ៤.២០០.៣៣៩ | ៧.២៨៨.៩៨៤ |
| ចំណេញក្នុងឆ្នាំ | - | ៦៧១.៧៤៣ | ៦៧១.៧៤៣ |
| ការបែងចែកភាគលាភ | - | (១.៣០០.០០០) | (១.៣០០.០០០) |
| **សមតុល្យគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦** | ៣.០៨៨.៦៤៥ | ៣.៥៧២.០៨២ | ៦.៦៦០.៧២៧ |
| *សមមូលនឹងពាន់រៀល* | ១២.៤៦៨.៨៦០ | ១៤.៤២០.៤៩៤ | ២៦.៨៨៩.៣៥៤ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី ១៣ ដល់ទំព័រទី ៥៥ គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

## ក្រុមហ៊ុន ឥណទានពលរដ្ឋរុងរឿង អិលធីឌី

## របាយការណ៍លំហូរសាច់ប្រាក់
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

| | កំណត់ | សម្រាប់ដំណាច់ឆ្នាំត្រឹម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | | សម្រាប់ដំណាច់ឆ្នាំត្រឹម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | |
|---|---|---|---|---|---|
| | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **លំហូរសាច់ប្រាក់ពីសកម្មភាព ប្រតិបត្តិការ** | | | | | |
| ចំណេញមុនដកពន្ធលើ ប្រាក់ចំណេញ | | ៩២៦.៨១៥ | ៣.៧៤១.៥៥២ | ៨៧១.៦២៧ | ៣.៥៣០.០៩០ |
| *និយ័តភាពលើ៖* | | | | | |
| ចំណូលការប្រាក់ | | (២.៨៦១.៩២៨) | (១១.៥៥៣.៦០៣) | (២.៣៣៤.២៨៧) | (៩.៤៥៣.៨៦២) |
| ចំណាយការប្រាក់ | | ៦១៥.៨៩៧ | ២.៤៨៦.៣៧៦ | ៣១៣.៥៦៦ | ១.២៦៩.៩៤២ |
| រំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងទ្រពសកម្មអរូបី | | ៥៦.២២៨ | ២២៦.៩៩២ | ៥៥.៤៦៥ | ២២៤.៦៣៣ |
| ការខាតពីការលក់ទ្រព្យសម្បត្តិ | | ៨.៦៣៦ | ៣៤.៨៦៤ | ២៦៦ | ១.០៧៧ |
| សំវិធានធនសម្រាប់ឥណទាន អាក្រក់ | | ១០៨.០៨៨ | ៤៣៦.៣៥១ | ៩១.១៤៥ | ៣៦៩.១៣៧ |
| សំវិធានធនប្រាក់បំណាច់ការងារ | | ៣៥.៤៨២ | ១៤៣.២៤១ | ៣០.២៣៩ | ១២២.៤៦៨ |
| *ការប្រែប្រួលនូវទុនចល័ត៖* | | | | | |
| ឥណទានផ្តល់ដល់អតិថិជន | | (២.០០៣.៦៧៥) | (៨.០៨៨.៨៣៦) | (១.៨៣៦.០៣៦) | (៧.៤៣៥.៩៤៦) |
| ទ្រព្យសកម្មផ្សេងៗ | | ១៤០.៧១២ | ៥៦៨.០៥៤ | (៣០.២៨១) | (១២២.៦៣៨) |
| បំណុលផ្សេងៗ | | (៦៧.៤៧០) | (២៧២.៣៧៦) | ១៥៥.៥៦៨ | ៦៣០.០៥០ |
| | | (៣.០៤១.២១៥) | (១២.២៧៧.៣៨៥) | (២.៦៨២.៧២៨) | (១០.៨៦៥.០៤៩) |
| ការប្រាក់បានទទួល | | ២.៨២៦.៣៥២ | ១១.៤០៩.៩៨៣ | ២.៣១៩.៤១៥ | ៩.៣៩៣.៦៣១ |
| ការប្រាក់បានបង់ | | (៥៧៧.៧១៨) | (២.៣៣២.២៤៨) | (៤២៧.១៥៦) | (១.៧២៩.៩៨២) |
| ពន្ធលើប្រាក់ចំណេញបានបង់ | | (២០០.៤៧២) | (៨០៩.៣០៥) | (២៥០.៦២៤) | (១.០១៥.០២៧) |
| ប្រាក់បំណាច់ការងារបានបង់ | | (៣២.៣០១) | (១៣០.៣៩៩) | (១១.៩៩៥) | (៤៨.៥៨០) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ ក្នុងសកម្មភាពប្រតិបត្តិការ** | ២១ | (១.០២៥.៣៥៤) | (៤.១៣៩.៣៥៤) | (១.០៥៣.០៨៨) | (៤.២៦៥.០០៧) |
| **លំហូរសាច់ប្រាក់ពីសកម្មភាព វិនិយោគ** | | | | | |
| ការទិញទ្រព្យ និងបរិក្ខារ | ៩ | (២៩.៨២៩) | (១២០.៤២០) | (៤១.៤៩៦) | (១៦៨.០៥៩) |
| ការទិញទ្រព្យសកម្មអរូបី | ១០ | - | - | (៦.៧៥០) | (២៧.៣៣៨) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុង សកម្មភាពវិនិយោគ** | | (២៩.៨២៩) | (១២០.៤២០) | (៤៨.២៤៦) | (១៩៥.៣៩៧) |

## ក្រុមហ៊ុន ឥណទានពលរដ្ឋរុងរឿង អិលធីឌី

## របាយការណ៍លំហូរសាច់ប្រាក់ (ត)
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

| | កំណត់សម្គាល់ | សម្រាប់ដំណាច់ឆ្នាំត្រឹម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | | សម្រាប់ដំណាច់ឆ្នាំត្រឹម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **លំហូរទឹកប្រាក់ពីសកម្មភាព ហិរញ្ញប្បទាន** | | | | | |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | | ២.០៨១.០៦១ | ៨.៤០១.២៤៣ | ៣.១៧០.២៩៤ | ១២.៨៣៩.៦៩១ |
| ការទូទាត់សងប្រាក់កម្ចី | | (៣៩៩.២៨៥) | (១.៦១១.៩១៤) | (៨០៦.៦៦៦) | (៣.២៦៦.៩៩៧) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ លើកម្ចី | | ៣.៤១៣ | ១៣.៧៧៨ | - | - |
| ភាគលាភបានបង់ | | (១.៣០០.០០០) | (៥.២៤៨.១០០) | - | - |
| **សាច់ប្រាក់សុទ្ធទទួលបានពី សកម្មភាពហិរញ្ញប្បទាន** | | ៣៨៥.១៨៩ | ១.៥៥៥.០០៧ | ២.៣៦៣.៦២៨ | ៩.៥៧២.៦៩៤ |
| ការកើនឡើង ឬថយចុះសុទ្ធ នូវសាច់ប្រាក់និង សាច់ប្រាក់សមមូល | | (៦៦៩.៩៩៤) | (២.៧០៤.៧៦៧) | ១.២៦២.២៩៤ | ៥.១១២.២៩០ |
| សាច់ប្រាក់ និងសាច់ប្រាក់ សមមូលនាដើមគ្រា | | ២.៣២៦.០៨៩ | ៩.៤២០.៦៦០ | ១.០៦៣.៧៩៥ | ៤.៣៣៤.៩៦៥ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (៣០.២៣៧) | - | (២៦.៥៩៥) |
| **សាច់ប្រាក់ និងសាច់ប្រាក់ សមមូលនាចុងគ្រា** | ២២ | ១.៦៥៦.០៩៥ | ៦.៦៨៥.៦៥៦ | ២.៣២៦.០៨៩ | ៩.៤២០.៦៦០ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយ ពីទំព័រទី ១៣ ដល់ទំព័រទី ៥៥ គឺជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

**ក្រុមហ៊ុន ឥណទានពលរដ្ឋរុងរឿង អិលធីឌី**

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦**

## ១. ព័ត៌មានទូទៅ

ក្រុមហ៊ុន **ឥណទានពលរដ្ឋរុងរឿង អិលធីឌី** (ហៅកាត់ថា "ក្រុមហ៊ុន") អតីតជាអង្គភាពឥណទានរបស់សម្ព័ន្ធសមាគមន៍ម៉ាស៊ីនកិនស្រូវកម្ពុជា ធ្វើសកម្មភាពអាជីវកម្មក្នុងការផ្តល់ហិរញ្ញប្បទានមីក្រូហិរញ្ញវត្ថុតាមរយៈសាខាចំនួន ៥ ដែលមានទីតាំងនៅ រាជធានីភ្នំពេញ ខេត្តបាត់ដំបង ខេត្តតាកែវ ស្រុកភ្នំព្រឹក (ខេត្តបាត់ដំបង) ខេត្តបន្ទាយមានជ័យ និងខេត្តពោធិ៍សាត់។

ក្រុមហ៊ុនបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្ម នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៥។ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា (ហៅកាត់ថា "ធនាគារកណ្តាល") ដើម្បីធ្វើប្រតិបត្តិការជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៥។ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណមីក្រូហិរញ្ញវត្ថុអចិន្ត្រៃយ៍ពីធនាគារកណ្តាល នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៨។

សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុន គឺការផ្តល់សេវាឥណទាន ដើម្បីធ្វើឲ្យកម្រិតជីវភាពរបស់ពលរដ្ឋកាន់តែមានភាពប្រសើរឡើង ក្នុងទិសដៅអភិវឌ្ឍជនបទតាមរយៈការិយាល័យកណ្តាលរបស់ក្រុមហ៊ុនដែលមានទីតាំងនៅរាជធានីភ្នំពេញ និងសាខាចំនួន៤ នៅតាមបណ្តាខេត្តមួយចំនួនដូចជា ខេត្តតាកែវ ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង និងខេត្តបន្ទាយមានជ័យ។

ទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុនមានទីតាំងស្ថិតនៅផ្ទះលេខ ៧៧៩A ផ្លូវកម្ពុជាក្រោម (១២៨) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រុមប្រឹក្សាភិបាលបានអនុម័តឲ្យចេញផ្សាយរបាយការណ៍ហិរញ្ញវត្ថុនេះ នៅថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៧។

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ

គោលការណ៍គណនេយ្យសំខាន់ៗដែលបានប្រើប្រាស់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះត្រូវបានបង្ហាញដូចខាងក្រោម។ គោលការណ៍គណនេយ្យទាំងនេះ ត្រូវបានអនុវត្តយ៉ាងស៊ីសង្វាក់គ្នាគ្រប់ឆ្នាំទាំងអស់ដែលបានបង្ហាញ លើកលែងតែមានបញ្ជាក់ផ្សេងពីនេះ។

## ២.១ មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលបានបង្ហាញជាប្រាក់ដុល្លារអាមេរិកត្រូវបានរៀបចំតាមវិធីសាស្ត្រថ្លៃដើម និងបានរៀបចំដោយអនុលោម ទៅតាមស្តង់ដារគណនេយ្យកម្ពុជា (ហៅកាត់ថា "CAS") និងគោលការណ៍ណែនាំរបស់ធនាគារកណ្តាល។

គោលការណ៍គណនេយ្យដែលបានប្រើប្រាស់អាចមានភាពខុសគ្នាពីគោលការណ៍គណនេយ្យដែលត្រូវបានគេទទួលស្គាល់ និងប្រើប្រាស់ជាទូទៅនៅតាមបណ្តាប្រទេស និងយុត្តាធិការផ្សេងៗ ។ របាយការណ៍ហិរញ្ញវត្ថុ ដែលបានភ្ជាប់មកជាមួយនេះ មិនមានបំណងបង្ហាញអំពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលហិរញ្ញវត្ថុ និង លំហូរសាច់ប្រាក់ ដោយអនុលោមទៅតាមយុត្តាធិការណាផ្សេងក្រៅពីព្រះរាជាណាចក្រកម្ពុជានោះទេ។ ដូចនេះរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ សម្រាប់បង្ហាញចំពោះតែអ្នកដែលបានជ្រាបអំពីគោលការណ៍គណនេយ្យ នីតិវិធី និងការអនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ។

## ២.សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.១ មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (ត)

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដែលស្របទៅតាមបទបញ្ញត្តិគណនេយ្យ គោលការណ៍ណែនាំពាក់ព័ន្ធរបស់ធនាគារកណ្តាល និង CAS តម្រូវឲ្យប្រើប្រាស់ការប៉ាន់ស្មាន និងការសន្មត ដែលមានផលប៉ះពាល់ដល់ចំនួនទ្រព្យសកម្ម និងបំណុល និងការលាតត្រដាងទ្រព្យសកម្ម និងបំណុលយថាភាពដែលបានរាយការណ៍ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុ និងប៉ះពាល់ដល់ចំនួននៃចំណូល និងចំណាយដែលបានរាយការណ៍នៅក្នុងអំឡុងពេលនៃការធ្វើរបាយការណ៍នេះ។ បើទោះជាការប៉ាន់ស្មានទាំងនេះផ្អែកទៅលើការយល់ដឹងដ៏សុក្រឹតបំផុតរបស់គណៈគ្រប់គ្រងទៅលើព្រឹត្តិការណ៍ និងសកម្មភាពផ្សេងៗនាពេលបច្ចុប្បន្នក៏ដោយ ក៏លទ្ធផលជាក់លាក់ចុងក្រោយអាចខុសពីការប៉ាន់ស្មានទាំងនេះ។ ផ្នែកដែលទាក់ទងនឹងការវិនិច្ឆ័យ ឬភាពស្មុគស្មាញក្នុងកម្រិតខ្ពស់ ឬផ្នែកដែលការសន្មត និងការប៉ាន់ស្មានមានលក្ខណៈជាសារវន្ត ចំពោះរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់ ៣។

### ២.២ ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ

នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៩ ក្រុមប្រឹក្សាជាតិគណនេយ្យ (ហៅកាត់ថា "NAC") នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ហៅកាត់ថា "MoEF") បានប្រកាសដាក់ឲ្យប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរ-ជាតិនៃកម្ពុជា (ហៅកាត់ថា "CIFRS") ដែលផ្អែកទាំងស្រុង ទៅតាមស្តង់ដារទាំងអស់ ដែលចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ រួមទាំងបំណកស្រាយ និងវិសោធនកម្មពាក់ព័ន្ធផ្សេងៗដែលអាចកើតមានក្នុងកាលៈទេសៈនានាចំពោះស្តង់ដារនីមួយៗ។ អង្គភាពដែលមានការទទួលខុសត្រូវ ជាសាធារណៈត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនឲ្យស្របទៅតាម CIFRS សម្រាប់ការិយបរិច្ឆេទគណនេយ្យដែលចាប់ផ្តើមនៅថ្ងៃទី១ ខែមករា ឆ្នាំ២០១២ ឬការិយបរិច្ឆេទគណនេយ្យបន្ទាប់ពីនេះ។

យោងតាមសារាចរណែនាំលេខ ០៨៦ សហវ-កជគ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២ NAC នៃ MoEF បានអនុម័តឲ្យធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ ពន្យារពេលអនុវត្ត CIFRS រហូតដល់ការិយបរិច្ឆេទដែលចាប់ផ្តើមនៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៦ ឬការិយបរិច្ឆេទគណនេយ្យ បន្ទាប់ពីនេះ។ នាថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ ក្រុមប្រឹក្សាជាតិគណនេយ្យបានចេញសេចក្តីជូនដំណឹងលេខ ០៥៨ សហវ-កជគ ទៅគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុស្តីពីការពន្យារពេលអនុវត្ត CIFRS រហូតដល់ការិយបរិច្ឆេទដែលចាប់ផ្តើមនៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ ឬការិយបរិច្ឆេទគណនេយ្យបន្ទាប់ពីនេះ ក្រោយពីមានការស្នើសុំដោយធនាគារកណ្តាលនាថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ២០១៦។

ស្តង់ដារគណនេយ្យដែលបានប្រើបច្ចុប្បន្ននេះ គឺមានភាពខុសគ្នាជាមួយនឹង CIFRS លើផ្នែកជាច្រើន។ ដូច្នេះការអនុវត្តន៍ CIFRS អាចមានផលប៉ះពាល់ខ្លាំងលើរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ។ គណៈគ្រប់គ្រងកំពុងធ្វើការវាយតម្លៃលើផលប៉ះពាល់ទាំងស្រុងនៃការផ្លាស់ប្តូរទៅ CIFRS ប៉ុន្តែមិនទាន់បាន បញ្ចប់នៅឡើយទេ គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ។

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.៣ មូលដ្ឋាននៃការសរុបរួម

របាយការណ៍ហិរញ្ញវត្ថុនេះ រួមបញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ទីស្នាក់ការកណ្តាល និង របាយ-ការណ៍ហិរញ្ញវត្ថុរបស់បណ្តាសាខានានា នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ រាល់សមតុល្យ និងប្រតិបត្តិការអន្តរសាខាសំខាន់ៗត្រូវបានលុបចោលទាំងស្រុងក្នុងការបូកសរុបសមតុល្យ។

### ២.៤ ការប្តូររូបិយប័ណ្ណ

*(ក) រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញ*

គណនីទាំងអស់ដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានវាស់តម្លៃដោយប្រើប្រាស់រូបិយប័ណ្ណនៃបរិយាកាសសេដ្ឋកិច្ចចម្បងដែលក្រុមហ៊ុនធ្វើប្រតិបត្តិការ (ហៅកាត់ថា "រូបិយប័ណ្ណគោល")។ គណៈគ្រប់គ្រងបានកំណត់យកប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណគោលរបស់ក្រុមហ៊ុន ដោយសារប្រាក់ដុល្លារអាមេរិកមានឥទ្ធិពលជាសារវន្តលើប្រតិបត្តិការរបស់ក្រុមហ៊ុន។ របាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិកដែលជារូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញរបស់ក្រុមហ៊ុន។

*(ខ) ប្រតិបត្តិការ និងសមតុល្យ*

ប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗ ក្រៅពីប្រាក់ដុល្លារអាមេរិកត្រូវបានកត់ត្រាប្តូរទៅជាប្រាក់ដុល្លារអាមេរិកតាមអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និងខាតពីការប្តូររូបិយប័ណ្ណ ដែលបណ្តាលមកពីការទូទាត់តាមប្រតិបត្តិការបែបនេះ និងពីការប្តូរទ្រព្យសកម្ម និងបំណុលរូបិយវត្ថុនានា ដែលកំណត់ជារូបិយប័ណ្ណផ្សេងៗ ក្រៅពីប្រាក់ដុល្លារអាមេរិកតាមអត្រាប្តូរនាដំណាច់ឆ្នាំ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល។

*(គ) ការបង្ហាញជាប្រាក់រៀល*

អនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ តម្រូវឲ្យកត់ត្រាប្តូររបាយការណ៍ហិរញ្ញវត្ថុពីប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀល។

ការកត់ត្រាប្តូរពីប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀល ត្រូវបានធ្វើឡើងដើម្បីអនុលោមតាមគោលការណ៍ណែនាំរបស់ធនាគារកណ្តាលទាក់ទិនទៅនឹងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ ដោយបានប្រើប្រាស់អត្រាប្តូរប្រាក់ផ្លូវការដែលបានប្រកាសដោយធនាគារកណ្តាល គឺ ១ដុល្លារអាមេរិកស្មើនឹង ៤.០៥០ រៀល (២០១៥៖ ១ដុល្លារអាមេរិកស្មើនឹង ៤.០៧៥រៀល)។

របាយការណ៍ហិរញ្ញវត្ថុ ដែលបង្ហាញជាប្រាក់រៀលនេះមិនមែនជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មទេ ដូចនេះមិនគួរបកស្រាយថា តួលេខនេះជាតួលេខសម្រាប់បង្ហាញដូចតួលេខជាប្រាក់ដុល្លារអាមេរិកនោះទេ ឬយល់ថាជាតួលេខត្រូវបានប្តូរ ឬអាចប្តូរទៅជាប្រាក់រៀល តាមអត្រាប្តូរប្រាក់ខាងលើ ឬអត្រាប្តូរប្រាក់ផ្សេងទៀតទេ។

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.៥ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

ដើម្បីរៀបចំរបាយការណ៍លំហូរសាច់ប្រាក់ គណនីសាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមានសាច់ប្រាក់ក្នុងដៃ សមតុល្យដែលមិនមានកម្រិតនៅធនាគារកណ្តាល និងសមតុល្យនៅធនាគារ និងការវិនិយោគសាច់ប្រាក់ងាយស្រួលរយៈពេលខ្លីដែលមានកាលកំណត់ដើមបីខែ ឬតិចជាង ដែលក្រុមហ៊ុនមានលទ្ធភាពពេញលេញក្នុងការដកយកសាច់ប្រាក់មកប្រើប្រាស់ ក្នុងគោលបំណងទូទៅតាមការចាំបាច់ និងមានការផ្លាស់ប្តូរតម្លៃតិចតួចបំផុត។

### ២.៦ ឥណទានអតិថិជន

ឥណទានផ្តល់ដល់អតិថិជន ដែលបានបង្ហាញនៅក្នុងតារាងតុល្យការ ត្រូវបានកត់ត្រាតាមថ្លៃដើម ដែលនៅសល់ដកចេញចំនួនទាំងឡាយណាដែលបានលុបចោលសំវិធានធនជាក់លាក់ និងសំវិធានធនទូទៅសម្រាប់ឥណទានអាក្រក់ និងជាប់សង្ស័យ។

ឥណទានត្រូវបានជម្រះចេញពីបញ្ជី នៅពេលដែលមិនមានភាពជាក់លាក់ថានឹងអាចប្រមូលបានមកវិញ។

### ២.៧ សំវិធានធនឥណទានអាក្រក់និងសង្ស័យ

ភាពគ្រប់គ្រាន់នៃសំវិធានធនឥណទានអាក្រក់ និងសង្ស័យត្រូវបានវាយតម្លៃប្រចាំខែដោយគណៈគ្រប់គ្រង។

ក្រុមហ៊ុនបានអនុវត្តការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធនតាមតម្រូវការរបស់ប្រកាសលេខ ធ៧-០២-១៨៦ ប្រ.ក. ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០២។ ប្រកាសនេះតម្រូវឲ្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងឡាយធ្វើ ចំណាត់ថ្នាក់សំពៀតឥណទានរបស់ខ្លួនជាបួនថ្នាក់ផ្អែកទៅតាមចំនួនថ្ងៃផុតកំណត់នៃប្រាក់ដើម និង/ឬ ការសងការប្រាក់ដូចខាងក្រោម ហើយត្រូវប្រាកដថា កម្រិតអប្បបរមានៃសំវិធានធនជាក់លាក់ ត្រូវបានកត់ត្រាអាស្រ័យទៅតាមចំណាត់ថ្នាក់ឥណទានពាក់ព័ន្ធ ដោយមិនគិតដល់ទ្រព្យសកម្ម ដែលបានដាក់ជាវត្ថុបញ្ចាំ (លើកលែងតែសាច់ប្រាក់) ដូចខាងក្រោម៖

| ចំណាត់ថ្នាក់ | ចំនួនថ្ងៃផុតកំណត់ | សំវិធានធន |
|---|---|---|
| *ឥណទានរយៈពេលខ្លី (១ឆ្នាំ ឬតិចជាង)៖* | | |
| ស្តង់ដារ | ០-២៩ ថ្ងៃ | ០% |
| ក្រោមស្តង់ដារ | ៣០-៥៩ ថ្ងៃ | ១០% |
| សង្ស័យ | ៦០-៨៩ ថ្ងៃ | ៣០% |
| បាត់បង់ | ៩០ ថ្ងៃឬច្រើនជាង | ១០០% |
| *ឥណទានរយៈពេលវែង (លើសពី១ឆ្នាំឡើងទៅ)៖* | | |
| ស្តង់ដារ | ០-២៩ ថ្ងៃ | ០% |
| ក្រោមស្តង់ដារ | ៣០-១៧៩ ថ្ងៃ | ១០% |
| សង្ស័យ | ១៨០-៣៥៩ ថ្ងៃ | ៣០% |
| បាត់បង់ | ៣៦០ ថ្ងៃឬច្រើនជាង | ១០០% |

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.៧ សំវិធានធនឥណទានអាក្រក់និងសង្ស័យ (ត)

បន្ថែមលើសំវិធានធនជាក់លាក់ខាងលើ ក្រុមហ៊ុនកត់ត្រាសំវិធានធនទូទៅបន្ថែម ក្នុងអត្រា ១% (២០១៥៖ ១%) លើឥណទានដែលនៅមិនទាន់ទូទាត់គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ ដោយផ្អែកទៅលើបទពិសោធន៍របស់ក្រុមហ៊ុន និងទស្សនវិស័យក្នុងអាជីវកម្ម។ គណៈគ្រប់គ្រងជឿជាក់ថា ការកត់ត្រាបែបនេះគឺមានលក្ខណៈសមហេតុផលជាងក្នុងការឆ្លុះបញ្ចាំងពីសំវិធានធនដែលចាំបាច់ក្នុងការស្រូបយកហានិភ័យ ដែលទាក់ទិនទៅនឹងបញ្ហានានាក្នុងបរិយាកាសម៉ាក្រូសេដ្ឋកិច្ច គ្រោះមហន្តរាយធម្មជាតិ និងស្ថានភាពយ៉ាប់យ៉ឺននៃការរកប្រាក់ចំណូលរបស់គ្រួសារ នៅតាមតំបន់ជនបទ ដែលកត្តាទាំងនេះអាចបណ្តាលឲ្យអតិថិជនមិនមានលទ្ធភាពសងប្រាក់ឥណទានដែលនៅមិនទាន់ទូទាត់។

ឥណទានត្រូវបានជម្រះចេញពីបញ្ជី នៅពេលដែលមិនមានភាពប្រាកដប្រជាអំពីការប្រមូលប្រាក់បានមកវិញ។ ឥណទានដែលប្រមូលបានមកវិញបន្ទាប់ពីបានជម្រះចេញពីបញ្ជីរួចហើយ ឬបានកត់ត្រាសំវិធានធនរួចហើយបានបន្ថយចំនួនសំវិធានធនឥណទានអាក្រក់និងសង្ស័យនៅក្នុងរបាយការណ៍លទ្ធផល។

### ២.៨ សំវិធានធនប្រាក់បំណាច់ការងារ

ក្រុមហ៊ុនផ្តល់ជូនបុគ្គលិករបស់ខ្លួននូវអត្ថប្រយោជន៍ប្រាក់បំណាច់ការងារ ដែលត្រូវបានគណនាតាមមូលដ្ឋានសមមាត្រ ក្នុងអត្រាស្មើនឹងប្រាក់បៀវត្សរ៍មួយខែ ជារៀងរាល់ឆ្នាំដែលបានបំពេញការងារពេញលេញ។

នៅពេលលាឈប់ពីការងារ ឬពេលចូលនិវត្តន៍ បុគ្គលិកដែលមានអតីតភាពការងារចំនួនបីឆ្នាំ ឬច្រើនជាងបីឆ្នាំ មានសិទ្ធិទទួលបានប្រាក់បំណាច់នេះទៅតាមចំនួនដែលបានបង្គរទុកសម្រាប់បុគ្គលិកម្នាក់ៗ។

ប្រាក់បំណាច់ការងារនេះត្រូវបានរក្សាទុកក្នុងគណនីចរន្ត ក្រោមឈ្មោះរបស់ក្រុមហ៊ុន ហើយបុគ្គលិកម្នាក់ៗមានសិទ្ធិដកយកប្រាក់នេះតែនៅពេលលាឈប់ពីការងារ ឬពេលចូលនិវត្តន៍តែប៉ុណ្ណោះ។

### ២.៩ ទ្រព្យសម្បត្តិ និងបរិក្ខារ

ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានតត់ត្រាថ្លៃដើមដករំលស់បង្គរ និងការខាតបង្គរដែលបណ្តាលមកពីការចុះថយតម្លៃ។ ថ្លៃដើមរួមមានចំណាយផ្ទាល់ផ្សេងៗក្នុងការនាំយកទ្រព្យសម្បត្តិនោះមកកាន់ទីតាំង និងលក្ខខណ្ឌចាំបាច់ដើម្បីឲ្យវាអាចធ្វើប្រតិបត្តិការទៅតាមការគ្រោងទុករបស់គណៈគ្រប់គ្រង។

ចំណាយបន្តបន្ទាប់ផ្សេងៗត្រូវបានកត់ត្រាបញ្ចូលទៅក្នុងតម្លៃនៃទ្រព្យនោះ ឬត្រូវបានកត់ត្រាជាទ្រព្យដាច់ដោយឡែកតាមការសមស្រប តែនៅពេលដែលមានភាពប្រាកដថាផលប្រយោជន៍សេដ្ឋកិច្ច នាពេលអនាគតនៃទ្រព្យនោះនឹងហូរចូលមកក្នុងក្រុមហ៊ុន ហើយថ្លៃដើមនៃទ្រព្យនោះ អាចត្រូវបានវាស់វែងគួរឲ្យជឿជាក់បានតែប៉ុណ្ណោះ។

តម្លៃយោងនៃផ្នែកដែលត្រូវបានជំនួសថ្មី ត្រូវបានជម្រះចេញ។ ចំណាយលើការជួសជុល និងការថែទាំផ្សេងៗទៀតទាំងអស់ ត្រូវបានកត់ត្រាជាបន្ទុកនៅក្នុងរបាយការណ៍លទ្ធផលក្នុងឆ្នាំដែលប្រតិបត្តិការនោះបានកើតឡើង។

ការធ្វើរំលស់លើទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកត់ត្រាជាបន្ទុកនៅក្នុងរបាយការណ៍លទ្ធផលតាមវិធីសាស្ត្ររំលស់ថេរ។

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.៩ ទ្រព្យសម្បត្តិ និងបរិក្ខារ (ត)

អាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់វាមានដូចខាងក្រោម៖

| | |
|---|---|
| អគារ | ២០ឆ្នាំ |
| ការកែលម្អទ្រព្យជួល | ៥ឆ្នាំ |
| កុំព្យូទ័រ និងបរិក្ខារការិយាល័យ | ៥ឆ្នាំ |
| គ្រឿងសង្ហារឹម និងបរិក្ខារភ្ជាប់ | ៥ឆ្នាំ |
| យានយន្ត | ៥ឆ្នាំ |

តម្លៃសំណល់ និងអាយុកាលប្រើប្រាស់របស់ទ្រព្យសកម្មត្រូវបានត្រួតពិនិត្យ និងធ្វើនិយ័តកម្មតាមការសមស្រប ប្រសិនបើមានសញ្ញាណនៃការប្រែប្រួលជាខ្លាំងណាមួយ ចាប់តាំងពីកាលបរិច្ឆេទរបាយការណ៍មុនមក។

តម្លៃយោងនៃទ្រព្យសកម្មណាមួយ ដែលលើសពីតម្លៃដែលអាចយកមកវិញបានរបស់វា ត្រូវបានកត់ត្រាបន្ថយភ្លាមឲ្យនៅត្រឹមតម្លៃប៉ាន់ស្មាន ដែលអាចយកមកវិញបាន។

ចំណេញ និងខាតពីការលក់ជម្រះទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកំណត់ដោយធ្វើការប្រៀបធៀប សាច់ប្រាក់បានពីការលក់ និងតម្លៃយោង ហើយត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផល។

### ២.១០ ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបី ដែលរួមមានអាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រដែលបានទិញ និងចំណាយពាក់ព័ន្ធរបស់វា ត្រូវបានកត់ត្រាតាមថ្លៃដើម ដករំលស់បង្គរ និងការខាតដែលបណ្តាលមកពីការថយចុះតម្លៃ។ អាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រដែលបានទិញ ត្រូវបានធ្វើមូលធនកម្មតាមមូលដ្ឋានថ្លៃដើមដែលបានកើតឡើងពេលទិញកម្មវិធីជាក់លាក់នោះមកប្រើប្រាស់។ ថ្លៃដើមទាំងនោះត្រូវបានធ្វើរំលស់ក្នុងអត្រា ២៥% ក្នុងមួយឆ្នាំដោយប្រើវិធីសាស្ត្ររំលស់ថេរ។

ចំណាយពាក់ព័ន្ធនឹងការថែរក្សាកម្មវិធីកុំព្យូទ័រ ត្រូវបានកត់ត្រាជាចំណាយនៅពេលដែលប្រតិបត្តិការនោះកើតឡើង។

### ២.១១ ការថយចុះតម្លៃនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ទ្រព្យសកម្មទាំងឡាយណាដែលត្រូវធ្វើរំលស់ ត្រូវបានត្រួតពិនិត្យរកការថយចុះតម្លៃរបស់វា នៅពេលដែលមានព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរកាលៈទេសៈណាមួយចង្អុលបង្ហាញថា តម្លៃយោងរបស់វានឹងមិនអាចយកមកវិញបាន។ ការខាតបង់បណ្តាលមកពីការថយចុះតម្លៃ ត្រូវបានកត់ត្រាតាមចំនួនលម្អៀងរវាងតម្លៃនៅសល់ នៃទ្រព្យនោះធៀបជាមួយតម្លៃ ដែលអាចយកមកវិញបាន។ តម្លៃដែលអាចយកមកវិញបានគឺជាតម្លៃមួយណា ដែលខ្ពស់ជាងគេរវាងតម្លៃសមស្របនៃទ្រព្យនោះ ដកចំណាយក្នុងការលក់ និងតម្លៃនៅប្រើប្រាស់។ ក្នុងការវាយតម្លៃដើម្បីរកការថយចុះទ្រព្យសម្បត្តិទាំងឡាយត្រូវបានបែងចែកជាក្រុមតូចៗបំផុត ដើម្បីកំណត់ពីលំហូរសាច់ប្រាក់របស់វានីមួយៗ (ឯកតាបង្កើតសាច់ប្រាក់)។

ការខាតដែលបណ្តាលមកពីការថយចុះតម្លៃ ត្រូវបានកត់ត្រាជាបន្ទុកក្នុងរបាយការណ៍លទ្ធផលក្នុងឆ្នាំដែលវាបានកើតឡើង។ ការកត់ត្រាត្រលប់មកវិញនៃការខាតដែលបណ្តាលមកពីការថយចុះតម្លៃត្រូវបានកត់ត្រាជាបន្ទុកក្នុងរបាយការណ៍លទ្ធផល ទៅតាមទំហំនៃតម្លៃយោងរបស់ទ្រព្យសកម្ម ដែលមិនលើសពីតម្លៃយោងដែលបានកំណត់កាត់កងនឹងរំលស់ ប្រសិនបើមិនបានកត់ត្រាការខាតដែលបណ្តាលមកពីការថយចុះតម្លៃ។

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.១២ ប្រាក់កម្ចី

ប្រាក់កម្ចីត្រូវបានកត់ត្រា តាមចំនួនប្រាក់ដើមដែលមិនទាន់ទូទាត់។ សោហ៊ុយផ្សេងៗដែលបានចំណាយដើម្បីទទួលបានប្រាក់កម្ចី ត្រូវបានកត់ត្រាក្នុងរបាយការណ៍លទ្ធផល។

### ២.១៣ សំវិធានធន

សំវិធានធនត្រូវបានកត់ត្រា នៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាល ហើយវាទំនងជាអាចតម្រូវឲ្យមានការចំណាយធនធានដើម្បីទូទាត់កាតព្វកិច្ចនោះ ហើយចំនួនទឹកប្រាក់ត្រូវបានប៉ាន់ស្មានគួរឲ្យជឿជាក់បាន។

នៅពេលដែលមានកាតព្វកិច្ចស្រដៀងគ្នាច្រើន កម្រិតនៃលំហូរចេញដើម្បីទូទាត់កាតព្វកិច្ចនោះត្រូវបានកំណត់ដោយគិតទៅលើចំណាត់ថ្នាក់នៃកាតព្វកិច្ចនោះទាំងមូល។ សំវិធានធនត្រូវបានកត់ត្រា ទោះបីជាកម្រិតលំហូរចេញនៃខ្ទង់ណាមួយ នៅក្នុងចំណាត់ថ្នាក់កាតព្វកិច្ចដូចគ្នានោះ មានចំនួនតូចក៏ដោយ។

### ២.១៤ ពន្ធលើប្រាក់ចំណេញ

ពន្ធលើប្រាក់ចំណេញក្នុងឆ្នាំ ត្រូវបានកត់ត្រាក្នុងរបាយការណ៍លទ្ធផល ហើយត្រូវបានគណនាតាមមូលដ្ឋានច្បាប់ពន្ធ ដែលបានអនុម័តរួចជាស្ថាពរ ឬអនុម័តរួចមួយផ្នែកធំគិតត្រឹមកាលបរិច្ឆេទតារាងតុល្យការនៅក្នុងព្រះរាជាណាចក្រកម្ពុជាជាប្រទេសដែលក្រុមហ៊ុនធ្វើប្រតិបត្តិការអាជីវកម្ម និងបង្កើតប្រាក់ចំណេញជាប់ពន្ធ។

ពន្ធពន្យារត្រូវបានធ្វើសំវិធានធន ដោយប្រើវិធីសាស្រ្តបំណុល ក្នុងតារាងតុល្យការលើលម្អៀង បណ្តោះអាសន្ន រវាងតម្លៃយោងនៃទ្រព្យសកម្មនិងបំណុលនៅក្នុងការរាយការណ៍របាយការណ៍ហិរញ្ញវត្ថុ និង ចំនួនដែលបានប្រើសម្រាប់ពន្ធដារ។ ចំនួនពន្ធពន្យារដែលបានកំណត់នោះ គឺផ្អែកលើលក្ខណៈដែលអាច ប្រើប្រាស់បាន ឬអាចកាត់កងបាននូវតម្លៃយោងរបស់ទ្រព្យសកម្ម និងបំណុល ដោយផ្អែកទៅតាមមូលដ្ឋាន ច្បាប់ពន្ធដែលបានអនុម័តរួចជាស្ថាពរ ឬអនុម័តរួចមួយផ្នែកធំគិតត្រឹមកាលបរិច្ឆេទរាយការណ៍។ ទ្រព្យសកម្មពន្ធពន្យារត្រូវបានកាត់កងជាមួយនឹងបំណុលពន្ធពន្យារ ប្រសិនបើមានសិទ្ធិតាមផ្លូវច្បាប់ ដើម្បីកាត់កងពន្ធទ្រព្យសកម្មក្នុងឆ្នាំជាមួយនឹងបំណុលពន្ធក្នុងឆ្នាំ ហើយប្រសិនបើវាទាក់ទងនឹងពន្ធលើប្រាក់ចំណេញ ដែលកំណត់ដោយអាជ្ញាធរពន្ធដារតែមួយទៅលើអង្គភាពជាប់ពន្ធតែមួយ។

ទ្រព្យសកម្មពន្ធពន្យារត្រូវបានកត់ត្រាលុះត្រាតែមានភាពប្រាកដថានឹងមានប្រាក់ចំណេញជាប់ពន្ធ នាពេលអនាគតសម្រាប់កាត់កងជាមួយនឹងលម្អៀងបណ្តោះអាសន្នដែលបានប្រើប្រាស់។ ទ្រព្យសកម្មពន្ធពន្យារត្រូវបានត្រួតពិនិត្យនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ និងត្រូវបានកាត់បន្ថយទៅតាមទំហំដែលទំនងជាមិនមានប្រាក់ចំណេញជាប់ពន្ធត្រូវបានកត់ត្រា។

### ២.១៥ ការកត់ត្រាចំណូល និងចំណាយការប្រាក់

ចំណូលការប្រាក់ បានមកពីឥណទាន ត្រូវបានកត់ត្រាតាមមូលដ្ឋានបង្គរដោយគិតទៅលើចំនួនប្រាក់ដើមនៃឥណទានដែលនៅមិនទាន់ទូទាត់។ នៅពេលដែលឥណទានក្លាយជាឥណទានមិនដំណើរការ (ការបង់ប្រាក់យឺត ៣០ ថ្ងៃឬច្រើនជាង) ការកត់ត្រាការប្រាក់ត្រូវបានព្យួរសិនរហូតដល់ពេលទទួលបានសាច់ប្រាក់ជាក់ស្តែង។

ចំណាយការប្រាក់លើប្រាក់កម្ចីត្រូវបានកត់ត្រាតាមមូលដ្ឋានបង្គរ។

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.១៦ ភតិសន្យា

ភតិសន្យា ដែលភាគីម្ចាស់ទ្រព្យនៅមានហានិភ័យជាក់លាក់ និងផលកម្មសិទ្ធិលើទ្រព្យនេះត្រូវបានចាត់ថ្នាក់ជាភតិសន្យាប្រតិបត្តិ។ ការទូទាត់ភតិសន្យាប្រតិបត្តិ (កាត់កងជាមួយនឹងការលើកទឹកចិត្តផ្សេងៗពីភាគីម្ចាស់ជួល) ត្រូវបានកត់ត្រាជាបន្ទុកក្នុងរបាយការណ៍លទ្ធផលតាមមូលដ្ឋានថេរលើរយៈពេលនៃភតិសន្យា។

## ៣. ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យគណនេយ្យសំខាន់ៗ

ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យត្រូវបានវាយតម្លៃជាបន្តបន្ទាប់ ផ្អែកទៅតាមបទពិសោធន៍ក្នុងគ្រាមុន និងកត្តាផ្សេងៗទៀត រួមមានការរំពឹងទុកនៃព្រឹត្តិការណ៍នាពេលអនាគត ដែលគេជឿជាក់ថាមានភាពសមហេតុផលទៅតាមកាលៈទេសៈផ្សេងៗ។ ក្រុមហ៊ុនធ្វើការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យដោយគិតទៅលើអនាគតកាល។ តាមនិយមន័យលទ្ធផលនៃការប៉ាន់ស្មានគណនេយ្យកម្រស្មើគ្នានឹងលទ្ធផលជាក់ស្តែងណាស់។ ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យ ដែលមានហានិភ័យជាខ្លាំងបណ្តាលឱ្យមាននិយ័តកម្មជាសារវន្តទៅលើតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលក្នុងឆ្នាំបន្ទាប់ត្រូវបានពិភាក្សាដូចខាងក្រោម៖

### ៣.១. ប្រភពសំខាន់ៗនៃការប៉ាន់ស្មានភាពមិនជាក់លាក់

#### (ក) សំវិធានធនឥណទានអាក្រក់និងសង្ស័យ

ក្រុមហ៊ុនអនុវត្តការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន តាមតម្រូវការរបស់ប្រកាសលេខ ធ៧-០២-១៨៦ ប្រ.ក. ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០២ របស់ធនាគារកណ្តាល។ ធនាគារកណ្តាលតម្រូវឲ្យគ្រឹះស្ថានមីក្រូ-ហិរញ្ញវត្ថុទាំងឡាយ ធ្វើចំណាត់ថ្នាក់សំពៀតឥណទានរបស់ខ្លួនជាបួនថ្នាក់ ហើយត្រូវប្រាកដថាកម្រិតអប្បបរមានៃសំវិធានធនជាក់លាក់ ត្រូវបានកត់ត្រាអាស្រ័យទៅតាមការធ្វើចំណាត់ថ្នាក់ពាក់ព័ន្ធ។ ក្នុងការធ្វើចំណាត់ថ្នាក់ឥណទានតម្រូវឲ្យក្រុមហ៊ុនគិតពិចារណាទៅលើប្រវត្តិនៃការសងប្រាក់ និងលក្ខខណ្ឌហិរញ្ញវត្ថុរបស់អ្នកខ្ចីប្រាក់។

បន្ថែមលើសំវិធានធនជាក់លាក់ក្រុមហ៊ុនកត់ត្រាសំវិធានធនបន្ថែមសម្រាប់ឥណទានអាក្រក់និងសង្ស័យក្នុងអត្រា ១% (២០១៥៖ ១%) លើឥណទានសរុបដែលនៅមិនទាន់ទូទាត់ដោយផ្អែកទៅលើបទពិសោធន៍របស់ក្រុមហ៊ុន និងទស្សនវិស័យក្នុងអាជីវកម្ម។

#### (ខ) ពន្ធ

ប្រព័ន្ធពន្ធដារនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានលក្ខណៈច្រើនប្រភេទ និងបញ្ញត្តិមានការផ្លាស់ប្តូរជាញឹកញាប់ ដែលជាទូទៅមានភាពមិនច្បាស់លាស់ មានភាពផ្ទុយគ្នា និងអាស្រ័យទៅលើការបកស្រាយ។ ពន្ធគឺត្រូវស្ថិតក្រោមការត្រួតពិនិត្យ និងការអង្កេតដោយអាជ្ញាធរ ដែលបានផ្តល់សិទ្ធិដោយច្បាប់ក្នុងការដាក់ពិន័យដាក់ទណ្ឌកម្ម និងបង់ការប្រាក់។

កត្តាទាំងនេះ អាចបង្កើតឲ្យមានហានិភ័យពន្ធយ៉ាងខ្លាំងសម្រាប់ក្រុមហ៊ុន។ អភិបាលជឿជាក់ថា ពួកគេមានការយល់ដឹងពីបទបញ្ញត្តិពន្ធដែលពាក់ព័ន្ធ និងបានធ្វើសំវិធានធន ដែលមានលក្ខណៈគ្រប់គ្រាន់ ដោយផ្អែកទៅលើការបកស្រាយនៃនីតិកម្មពន្ធ។ ក៏ប៉ុន្តែអាជ្ញាធរជាប់ពាក់ព័ន្ធ អាចនឹងមានបំណកស្រាយខុសគ្នា ហើយផលប៉ះពាល់អាចមានទំហំធំ។ នៅពេលដែលលទ្ធផលពន្ធចុងក្រោយខុសគ្នាពីចំនួនដែលបានកត់ត្រាពីដំបូង នោះភាពលម្អៀងនេះនឹងធ្វើឱ្យប៉ះពាល់ដល់ពន្ធលើប្រាក់ចំណេញ និងសំវិធានធនពន្ធពន្យារនៅក្នុងឆ្នាំ ដែលការកំណត់ពន្ធបានធ្វើឡើង។

## ៣. ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យគណនេយ្យសំខាន់ៗ (ត)

### ៣.២. ការវិនិច្ឆ័យសំខាន់ៗក្នុងការអនុវត្តគោលនយោបាយគណនេយ្យ

មិនមានការវិនិច្ឆ័យសំខាន់ៗដែលធ្វើឡើងដោយគណៈគ្រប់គ្រង ក្នុងដំណើរការអនុវត្តគោលនយោបាយគណនេយ្យ ដែលមានឥទ្ធិពលជាខ្លាំងទៅលើចំនួនទឹកប្រាក់ ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ក្រៅពីការប៉ាន់ស្មានដែលបានរៀបរាប់ខាងលើឡើយ។

## ៤. សាច់ប្រាក់ក្នុងដៃ

| | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ការិយាល័យកណ្តាល (រាជធានីភ្នំពេញ) | ១១.០៦៤ | ៤៤.៦៦៥ | ២.៤២៦ | ៩.៨២៥ |
| សាខានៅតាមបណ្តាខេត្ត | | | | |
| ខេត្តតាកែវ | ២០.០០៤ | ៨០.៧៥៦ | ៣១.៩៦៨ | ១២៩.៤៧០ |
| ខេត្តពោធិ៍សាត់ | ១៧.៥៨០ | ៧០.៩៧០ | ២០.៣៤៦ | ៨២.៤០៣ |
| ស្រុកភ្នំព្រឹក | ១១.៤២២ | ៤៦.១១១ | ១៧.១៤៤ | ៦៩.៤៣៣ |
| ខេត្តបាត់ដំបង | ១៦.៩៧៦ | ៦៨.៥៣២ | ១៦.៣៥៩ | ៦៦.២៥៤ |
| ខេត្តបន្ទាយមានជ័យ | ៩.៣២៦ | ៣៧.៦៥០ | ៦.៦០៩ | ២៦.៧៦៦ |
| | ៨៦.៣៧២ | ៣៤៨.៦៨៤ | ៩៤.៨៥២ | ៣៨៤.១៥១ |

## ៥. សមតុល្យនៅធនាគារកណ្តាល

| | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| គណនីចរន្ត | ១.២៥៦ | ៥.០៧០ | ៩៥១ | ៣.៨៥១ |
| ប្រាក់តម្កល់ធានាលើដើមទុន* | ១៥៤.៤៣២ | ៦២៣.៤៤២ | ១៥៤.៤៣២ | ៦២៥.៤៥០ |
| | ១៥៥.៦៨៨ | ៦២៨.៥១២ | ១៥៥.៣៨៣ | ៦២៩.៣០១ |

* អនុលោមតាមប្រកាសលេខ ធ៧-០៦-២០៩ប្រ.ក. ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៦ ស្តីពីការផ្តល់ អាជ្ញាប័ណ្ណដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនតម្រូវឲ្យតម្កល់ប្រាក់ធានាលើដើមទុននៅធនាគារកណ្តាលចំនួន ៥% នៃដើមទុនបានបង់របស់ក្រុមហ៊ុន។ ប្រាក់តម្កល់នេះនឹងត្រូវបង្វិលជូនក្រុមហ៊ុនវិញ នៅពេលក្រុមហ៊ុនស្ម័គ្រចិត្តបញ្ចប់ប្រតិបត្តិការអាជីវកម្មរបស់ខ្លួន។

ប្រាក់តម្កល់ធានាលើដើមទុនជាប្រាក់ដុល្លារអាមេរិកទទួលបានការប្រាក់ពីចំនួន ០.២០%ទៅ ០.២២% ក្នុងមួយឆ្នាំ (២០១៥៖ ០.១១%)។ ការទូទាត់ការប្រាក់ត្រូវធ្វើឡើងប្រចាំឆមាស។

### ៦. ប្រាក់បញ្ញើនៅធនាគារ

| | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| *ធនាគារក្នុងស្រុក៖* | | | | |
| គណនីចរន្ត | ៤៩៩.២៣៣ | ២.០១៥.៤០៤ | ១.០៤៤.០១១ | ៤.២២៨.២៤៥ |
| គណនីសន្សំ | ១.០៦៩.២៣៤ | ៤.៣១៦.៤៩៧ | ៥៨៦.២៧៥ | ២.៣៧៤.៤១៣ |
| ប្រាក់បញ្ញើមានកាលកំណត់ | ១២.៥០០ | ៥០.៤៦៣ | ៦១២.៥០០ | ២.៤៨០.៦២៥ |
| | ១.៥៨០.៩៦៧ | ៦.៣៨២.៣៦៤ | ២.២៤២.៧៨៦ | ៩.០៨៣.២៨៣ |

អត្រាការប្រាក់ប្រចាំឆ្នាំលើសមតុល្យប្រាក់បញ្ញើនៅធនាគារ ត្រូវបានសង្ខេបដូចខាងក្រោម៖

| | **២០១៦** | **២០១៥** |
|---|---|---|
| គណនីចរន្ត | 0% | 0% |
| គណនីសន្សំ | 0.១៥% - 0.២៥% | 0.0៥% - 0.២៥% |
| ប្រាក់បញ្ញើមានកាលកំណត់ | ៣.២៥% | ២.៥0% - ៤.៥0% |

### ៧. ឥណទានផ្តល់ដល់អតិថិជន

| | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ឥណទានឯកត្តជន | ១១.៣០២.២២១ | ៤៥.៦២៧.០៦៦ | ៩.៣៨៩.០១៤ | ៣៨.០២៥.៥០៧ |
| | ១១.៣០២.២២១ | ៤៥.៦២៧.០៦៦ | ៩.៣៨៩.០១៤ | ៣៨.០២៥.៥០៧ |
| សំវិធានធនសម្រាប់ឥណទានអាក្រក់ និងជាប់សង្ស័យ៖ | | | | |
| ជាក់លាក់ | (៧៥.៤៤៤) | (៣០៤.៥៦៧) | (៧៦.០០៧) | (៣០៧.៨២៨) |
| ទូទៅ | (១១០.៩០៩) | (៤៤៧.៧៤០) | (៩២.៧២៦) | (៣៧៥.៥៤១) |
| | (១៨៦.៣៥៣) | (៧៥២.៣០៧) | (១៦៨.៧៣៣) | (៦៨៣.៣៦៩) |
| | ១១.១១៥.៨៦៨ | ៤៤.៨៧៤.៧៥៩ | ៩.២២០.២៨១ | ៣៧.៣៤២.១៣៨ |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦**

## ៧. ឥណទានផ្តល់ដល់អតិថិជន (ត)

បម្រែបម្រួលនៃសំវិធានធនសម្រាប់ឥណទានអាក្រក់ និងជាប់សង្ស័យមានដូចខាងក្រោម៖

| | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| នាដើមឆ្នាំ | ១៦៨.៧៣៣ | ៦៨៣.៣៦៩ | ១០៧.៧៣៨ | ៤៣៩.០៣៣ |
| សំវិធានធនក្នុងឆ្នាំ | ១០៨.០៨៨ | ៤៣៦.៣៥១ | ៩១.១៤៥ | ៣៦៩.១៣៧ |
| ជម្រះចេញពីបញ្ជីក្នុងឆ្នាំ | (៩០.៨៨៤) | (៣៦៦.៨៩៩) | (២៧.២៦១) | (១១០.៩០៧) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | ៤១៦ | (៥១៤) | (២.៨៨៩) | (១៤.៣៩៤) |
| នាដំណាច់ឆ្នាំ | ១៨៦.៣៥៣ | ៧៥២.៣០៧ | ១៦៨.៧៣៣ | ៦៨៣.៣៦៩ |

ឥណទានផ្តល់ដល់អតិថិជនត្រូវបានវិភាគដូចខាងក្រោម៖

### (ក) វិភាគតាមកាលផុតកំណត់

| | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| មិនលើស១ខែ | ៥២៥.០៥២ | ២.១១៩.៦៣៥ | ៤៨០.៨៦៦ | ១.៩៤៧.៥០៨ |
| ពី១ខែ-៣ខែ | ២.៣៦៤.៥៤៦ | ៩.៥៤៥.៦៧២ | ២.៦៤០.២៤៣ | ១០.៦៩២.៩៨៤ |
| ពី៣ខែ-១២ខែ | ១.៦១៤.០៦៤ | ៦.៥១៥.៩៧៦ | ២.៦៧២.៩០៥ | ១០.៨២៥.២៦៥ |
| លើសពី១២ខែឡើងទៅ | ៦.៧៩៨.៥៥៩ | ២៧.៤៤៥.៧៨៣ | ៣.៥៩៥.០០០ | ១៤.៥៥៩.៧៥០ |
| | ១១.៣០២.២២១ | ៤៥.៦២៧.០៦៦ | ៩.៣៨៩.០១៤ | ៣៨.០២៥.៥០៧ |

### (ខ) វិភាគតាមប្រភេទរូបិយប័ណ្ណ

| | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ប្រាក់ដុល្លារអាមេរិក | ៩.៣៣៣.១៨៧ | ៣៧.៦៧៨.០៧៦ | ៦.៨២៥.៧៣២ | ២៧.៦៤៤.២១៥ |
| ប្រាក់បាត | ១.៣៦៦.១០១ | ៥.៥១៤.៩៥០ | ១.៥៨០.៦១២ | ៦.៤០១.៤៧៩ |
| ប្រាក់រៀល | ៦០២.៩៣៣ | ២.៤៣៤.០៤០ | ៩៨២.៦៧០ | ៣.៩៧៩.៨១៣ |
| | ១១.៣០២.២២១ | ៤៥.៦២៧.០៦៦ | ៩.៣៨៩.០១៤ | ៣៨.០២៥.៥០៧ |

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦**

## ៧. ឥណទានផ្តល់ដល់អតិថិជន (ត)

### (គ) វិភាគតាមប្រភេទអាជីវកម្ម

| | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| កសិកម្ម | ១០.៧៤៤.៩១២ | ៤៣.៣៧៧.២១០ | ៨.៨១៧.២៨៤ | ៣៥.៧១០.០០០ |
| សេវាកម្ម | ៤១៦.៣២០ | ១.៦៨០.៦៨៤ | ៣៩៦.៧៤១ | ១.៦០៦.៨០១ |
| ផ្សេងៗ | ១៤០.៩៨៩ | ៥៦៩.១៧២ | ១៧៤.៩៨៩ | ៧០៨.៧០៦ |
| | ១១.៣០២.២២១ | ៤៥.៦២៧.០៦៦ | ៩.៣៨៩.០១៤ | ៣៨.០២៥.៥០៧ |

### (ឃ) វិភាគតាមការតាំងទីលំនៅ

| | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| និវេសនជន | ១១.៣០២.២២១ | ៤៥.៦២៧.០៦៦ | ៩.៣៨៩.០១៤ | ៣៨.០២៥.៥០៧ |

### (ង) វិភាគតាមទំនាក់ទំនង

| | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ឥណទានអតិថិជនខាងក្រៅ | ១១.២២២.០០៨ | ៤៥.៣០៣.២៤៦ | ៩.៣៨៩.០១៤ | ៣៨.០២៥.៥០៧ |
| ឥណទានផ្តល់ដល់បុគ្គលិក | ៨០.២១៣ | ៣២៣.៨២០ | - | - |
| | ១១.៣០២.២២១ | ៤៥.៦២៧.០៦៦ | ៩.៣៨៩.០១៤ | ៣៨.០២៥.៥០៧ |

## ៧. **ឥណទានផ្តល់ដល់អតិថិជន** (ត)

### (ច) **វិភាគតាមចំណាត់ថ្នាក់ឥណទាន**

| | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| *ឥណទានគ្មានការធានា** | | | | |
| ឥណទានធម្មតា | ១១.០៩០.៩០៨ | ៨៤.៧៧៣.៩៩៦ | ៩.២៦២.១៦៤ | ៣៧.៥១១.៧៦៤ |
| ឥណទានក្រោមស្តង់ដារ | ១១៣.១២២ | ៤៥៦.៦៧៤ | ៤១.៣៥៥ | ១៦៧.៤៨៨ |
| ឥណទានសង្ស័យ | ៤៨.៦៥៦ | ១៩៦.៤២៤ | ១៨.៤៨០ | ៧៤.៨៤៤ |
| ឥណទានបាត់បង់ | ៤៩.៥៣៥ | ១៩៩.៩៧២ | ៦៧.០១៥ | ២៧១.៤១១ |
| | ១១.៣០២.២២១ | ៤៥.៦២៧.០៦៦ | ៩.៣៨៩.០១៤ | ៣៨.០២៥.៥០៧ |

* ឥណទានគ្មានការធានាតំណាងឲ្យឥណទានដែលពុំមានទ្រព្យបញ្ចាំ និងឥណទានដែលធានាដោយប្លង់ទន់ដែលពុំមែនចេញដោយអគ្គនាយកដ្ឋានសុរិយោដី។

### (ឆ) **វិភាគតាមទីតាំង**

| | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| រាជធានីភ្នំពេញ | ៨០.២១៣ | ៣២៣.៨២០ | - | - |
| ស្រុកភ្នំព្រឹក | ១.៥៤៨.៧១៤ | ៦.២៥២.១៥៨ | ៣.៤៧១.៧៦៤ | ១៤.០៦០.៦៤៤ |
| ខេត្តពោធិ៍សាត់ | ២.០៥៩.៦៧១ | ៨.៣១៩.៨៩២ | ២.២៧១.៦៥៧ | ៩.២០០.២១១ |
| ខេត្តតាកែវ | ១.៤៦៥.៤៦៧ | ៥.៩១៦.០៩០ | ១.៨១៥.០៨២ | ៧.៣៥១.០៨២ |
| ខេត្តបាត់ដំបង | ៥.៣៧៨.៣២៧ | ២១.៧១២.៣០៦ | ១.៣៨៥.៤៧២ | ៥.៤៨៩.១៦២ |
| ខេត្តបន្ទាយមានជ័យ | ៧៦៩.៨២៩ | ៣.១០៧.៨០០ | ៤៨៥.០៣៩ | ១.៩៦៤.៤០៨ |
| | ១១.៣០២.២២១ | ៤៥.៦២៧.០៦៦ | ៩.៣៨៩.០១៤ | ៣៨.០២៥.៥០៧ |

## ៧. ឥណទានផ្តល់ដល់អតិថិជន (ត)

### (ង) វិភាគតាមអត្រាការប្រាក់ (ក្នុងមួយឆ្នាំ)

#### (i) វិភាគតាមទំនាក់ទំនង

| | ២០១៦ | ២០១៥ |
|---|---|---|
| ឥណទានអតិថិជនខាងក្រៅ | ២០.៤% - ៣៦.០% | ២០.៤% - ៣៦.០% |
| ឥណទានផ្តល់ដល់បុគ្គលិក | ១៥.៦% | - |

#### (ii) វិភាគតាមប្រភេទរូបិយប័ណ្ណ

| | ២០១៦ | ២០១៥ |
|---|---|---|
| ប្រាក់ដុល្លារអាមេរិក | ១៥.៦% - ៣៦.០% | ២០.៤% - ៣៤.៨% |
| ប្រាក់បាត | ២៥.០% - ៣៤.៨% | ២៤.០% - ៣៦.០% |
| ប្រាក់រៀល | ២៥.២% - ៣៦.០% | ២៥.២% - ៣៦.០% |

## ៨. ទ្រព្យសកម្មផ្សេងៗ

| | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦ | | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| បង្គរការប្រាក់ត្រូវទទួល | ៣៧៣.៤២៦ | ១.៥០៧.៥២១ | ៣៣៧.៨៤៣ | ១.៣៦៨.២៦៤ |
| ការបង់មុន | ៣១.៩០៣ | ១២៨.៧៩២ | ២៩.៣៨១ | ១១៨.៩៩៣ |
| គណនីអតិថិជនផ្សេងៗ | ២.៨១៣ | ១១.៣៥៦ | ១៤៦.០៤៧ | ៥៩១.៤៩៣ |
| | ៤០៨.១៤២ | ១.៦៤៧.៦៦៩ | ៥១៣.២៧១ | ២.០៧៨.៧៥០ |

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៦

### ៩. ទ្រព្យសម្បត្តិនិងបរិក្ខារ

| | អគារ | ការកែលម្អលើទ្រព្យជួល | កុំព្យូទ័រនិងបរិក្ខារការិយាល័យ | គ្រឿងសង្ហារឹមនិងបរិក្ខារភ្ជាប់ | យានយន្ត | ទ្រព្យកំពុងដំណើរការ | សរុប |
|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **ថ្លៃដើម** | | | | | | | |
